ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ០១២ ស.ស.ក ប.ស្ក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញចំណារ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥
- យោងតាមតម្រូវការចាំបាច់ ។/ៗ



អគារលេខ៤៨ មហាវិថីសម្តេចព្រះសីហនុ ទន្លេបាសាក់ ចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារបច្ចេកទេសតាក់តែងសេចក្ដីព្រាងក្រមបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ង ឌុល្លី** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ស៊ុម សុខម្ភ** | ជំនួយការអមក្រសួង និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន | អនុប្រធាន |
| ៣- ឯកឧត្តម **កែន សេរីរដ្ឋា** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ ដោយចីរភាព | សមាជិក |
| ៤- លោក **ជ្រិន សុខា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន | សមាជិក |
| ៥- លោក **មាស សុផល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | សមាជិក |
| ៦- លោក **សេខ សោត** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | សមាជិក |
| ៧- លោក **គីម ណុខ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | សមាជិក |
| ៨- លោក **ឡុខ រិទ្ធីរក្ស** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន | សមាជិក |
| ៩- លោក **រាត់ ស៊ិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន | សមាជិក |
| ១០- តំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធតាមវិស័យ | | សមាជិកអញ្ជើញ |
| ១១- និងអ្នកជំនាញការជាតិ និង/ឬអន្តរជាតិតាមវិស័យ | | សមាជិកអញ្ជើញ |

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងបរិស្ថានអាចបង្កើតក្រុមការងារជំនាញផ្សេងទៀត តាមសំណើរបស់ប្រធានក្រុមការងារបច្ចេកទេស។

**ប្រការ ២.-**

ក្រុមការងារបច្ចេកទេសតាក់តែងសេចក្ដីព្រាងក្រមបរិស្ថានជាសេនាធិការរបស់ក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំតាក់តែងសេចក្ដីព្រាងក្រមបរិស្ថាន ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគលិខិតូបករណ៍គតិយុត្តជាតិ និងអន្តរជាតិ ដែលមានវិសាលភាពអនុវត្តក្នុងវិស័យបរិស្ថាន
- សិក្សា វិភាគមុខងារស្ថាប័ន និងស្នើដំណោះស្រាយ ក៏ដូចជាវិធានការនានា ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យនិងសម្រេច ឬផ្ដល់អនុសាសន៍ណែនាំលើបញ្ហាវិវាទសមត្ថកិច្ចរវាងក្រសួង ឬស្ថាប័នរដ្ឋ និងការឯកភាពលើផ្ទៃប្រទេស

- សិក្សានិងលើកសំណើកំណត់ទស្សនៈវិស័យយូរអង្វែង ដើម្បីឈានទៅកសាង និងអភិវឌ្ឍគោលនយោបាយនីតិកម្មសម្រាប់គ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ អភិរក្សជីវៈចម្រុះ និងលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព
- កំណត់គោលការណ៍ទូទៅនៃក្រមបរិស្ថាននិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគោលនយោបាយរួមរបស់ជាតិ សម្រាប់គ្រប់គ្រងធនធានធម្មជាតិ
- ធ្វើបច្ចុប្បន្នកម្មយន្តការច្បាប់ដែលអនុគ្រោះដល់ការប្រើប្រាស់បច្ចេកវិជ្ជា និងវិទ្យាសាស្ត្រថ្មីៗ សមស្របតាមការវិវត្តន៍នៃសម័យកាល
- ចុះសិក្សា ស្រាវជ្រាវអំពីទីតាំងភូមិសាស្ត្រជាក់ស្តែង ដើម្បីកសាងនិងអភិវឌ្ឍស្តង់ដារបរិស្ថាន យន្តការគាំពារនិងលើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប
- អភិវឌ្ឍនយោបាយព្រហ្មទណ្ឌ និងយន្តការនានាដែលចាំបាច់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការដាក់ឱ្យអនុវត្តក្រមបរិស្ថាន
- សហការជាមួយនឹងក្រសួង និង/ឬអាជ្ញាធរសាធារណៈមានសមត្ថកិច្ចពាក់ព័ន្ធក្នុងកិច្ចការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ ដើម្បីប្រមូល ចងក្រង សិក្សា និងបង្កើតយន្តការនានាដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តក្រមបរិស្ថាននិងលិខិតូបករណ៍គតិយុត្ត ដែលពាក់ព័ន្ធ
- សហការជាមួយនឹងជំនាញការជាតិ និងអន្តរជាតិដើម្បីរៀបចំតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន កំណត់បង្ហាញ និងសេចក្តីថ្លែងហេតុ
- មានសិទ្ធិអញ្ជើញតំណាងនាយកដ្ឋានជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អ្នកជំនាញការជាតិ និងអន្តរជាតិ តាមការចាំបាច់
- លើកសំណើសុំនិរាករណ៍ ឬធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតយុត្តដែលពាក់ព័ន្ធ
- រៀបចំរបាយការណ៍ចុះត្រួតពិនិត្យទីតាំង និងរបាយការណ៍ស្តីពីវឌ្ឍនភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ និងឆមាស ដើម្បីដាក់ជូនក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំតាក់តែងសេចក្តីព្រាងក្រមបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងចាត់វិធានការបន្តតាមមុខការ
- ផ្សព្វផ្សាយ និង/ឬបោះពុម្ពផ្សាយជាសាធារណៈនូវស្នាដៃនានាដែលខ្លួនបង្កើតបាន
- អនុវត្តការងារផ្សេងៗទៀតដែលក្រុមការងារអន្តរក្រសួងប្រគល់ជូន។

**ប្រការ ៣.-**

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ដោយមានកិច្ចសហការជាមួយក្រុមមេធាវីវិស្គ្ក មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំបង្កើតនិងដឹកនាំការអនុវត្តរាល់យន្តការនានាដែលចាំបាច់សម្រាប់លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន
- ដឹកនាំកិច្ចប្រជុំអន្តរជំនាញ តាមការចាំបាច់
- រៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង អនុលោមតាមការចាំបាច់

- រៀបចំបែបបទ និងកិច្ចគាំពារខាងមធ្យោបាយ និងសម្ភារៈនានា ដែលចាំបាច់សម្រាប់ចុះទស្សនកិច្ចសិក្សា តាមទីតាំងភូមិសាស្ត្រពាក់ព័ន្ធនានា តាមសំណើរបស់ក្រុមការងារជំនាញ
- រៀបចំសិក្ខាសាលា និងសន្និសីទនានា ស្របតាមផែនការសកម្មភាពរបស់ខ្លួន
- រៀបចំផែនការសកម្មភាព និងកៀងគរជំនួយនានាដែលចាំបាច់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការតាក់តែងនិងផ្សព្វផ្សាយជាសាធារណៈ នូវខ្លឹមសារនិងស្មារតីនៃសេចក្តីព្រាងក្រមបរិស្ថាន
- គ្រប់គ្រងការអនុវត្តគម្រោង និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុជូនដៃគូអភិវឌ្ឍន៍នានា
- កំណត់លក្ខខណ្ឌ បែបបទ និងនីតិវិធីដើម្បីជ្រើសរើសអ្នកជំនាញការ អ្នកស្រាវជ្រាវជាន់ខ្ពស់ជាតិ ជំនួយការច្បាប់ និងអ្នកជំនាញ ព្រមទាំងអ្នកបកប្រែ អនុលោមលក្ខខណ្ឌនានាដែលក្រសួងបរិស្ថាន និងដៃគូអភិវឌ្ឍន៍បានព្រមព្រៀង
- សម្របសម្រួលការងាររដ្ឋបាល និងទំនាក់ទំនងសាធារណៈដែលចាំបាច់សម្រាប់ធានាប្រសិទ្ធភាពនៃការរៀបចំតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ជាអាទិ៍ៈ ការចងក្រងនិងចែកចាយលទ្ធផលនៃការសិក្សា ស្រាវជ្រាវ និងវិភាគ ការងារបកប្រែគ្រប់ប្រភេទ និងការរក្សាទុកឯកសារនានា ជូនជាប្រយោជន៍ដល់ក្រុមការងារបច្ចេកទេសតាក់តែងក្រមបរិស្ថាន។

**ប្រការ ៤.-**

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ជាសេនាធិការនៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ស៊ឹម សុខម្ភ** | ជំនួយការអមក្រសួងបរិស្ថាន | ប្រធាន |
| ២- លោកស្រី | **សៅ កញ្ញា** | ប្រធានក្រុមមេធាវីវិល្ហ និងសហភាតា | អនុប្រធាន |
| ៣- លោក | **ទេព ណៃរត** | អនុប្រធានក្រុមមេធាវីវិល្ហ និងសហភាតា | សមាជិក |
| ៤- លោក | **Brian Rohan** | អ្នកជំនាញការប្រចាំក្រុមមេធាវីវិល្ហ | សមាជិក |
| ៥- លោក | **Matthew Baird** | អ្នកជំនាញការប្រចាំក្រុមមេធាវីវិល្ហ | សមាជិក |
| ៦- លោក | **សំ ឡុខ** | មេធាវីប្រចាំក្រុមមេធាវីវិល្ហ | សមាជិក |
| ៧- លោក | **ណាខ សារ៉ាយ** | មេធាវីប្រចាំក្រុមមេធាវីវិល្ហ | សមាជិក |
| ៨- លោក | **អុល ប៊ុនធឿន** | ជំនួយការច្បាប់ប្រចាំក្រុមមេធាវីវិល្ហ | សមាជិក |
| ៩- លោក | **សន ប៊ុនមាន** | មន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ១០- លោក | **សៅ ឈុំពិសិដ្ឋ** | មន្ត្រីក្រសួងបរិស្ថាន | សមាជិក |

**ប្រការ ៥.-**

ក្រុមការងារជំនាញនិរន្តរភាពទីក្រុង និងសេដ្ឋកិច្ចបៃតង ជាសេនាធិការនៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងមានសមាសភាពដូចខាងក្រោមៈ



YCH

| | | |
|---|---|---|
| ១- ឯកឧត្តម **កែន សេរីរដ្ឋា** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | ប្រធាន |
| ២- លោក **ជាញ់ សេរី** | ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | អនុប្រធាន |
| ៣- លោក **ប៉ាក សុខារ៉ាឌុត** | ប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសម្លេង | សមាជិក |
| ៤- លោក **តាំង ម៉េងអៀង** | ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង | សមាជិក |
| ៥- តំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ | | សមាជិកអញ្ជើញ |
| ៦- អ្នកជំនាញការជាតិ និង/ឬអន្តរជាតិ | | សមាជិកអញ្ជើញ |

ប្រធានក្រុមការងារបច្ចេកទេស ឬប្រធានក្រុមការងារជំនាញនិរន្តរភាពទីក្រុង និងសេដ្ឋកិច្ចបៃតង អាចស្នើសុំបន្ថែមសមាជិករបស់ខ្លួន តាមការចាំបាច់។ ការតែងតាំងនេះត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ ៦.-**

ក្រុមការងារជំនាញនិរន្តរភាពទីក្រុង និងសេដ្ឋកិច្ចបៃតង មានតួនាទី និងភារកិច្ចជាសារវន្តដូចខាងក្រោម៖

ក. សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគប្រៀបធៀបច្បាប់ បទដ្ឋានគតិយុត្តជាធរមាន និងបទពិសោធន៍ល្អៗដែលមាន ដើម្បីស្នើចេញនូវខ្លឹមសារនៃសេចក្តីព្រាងបទប្បញ្ញត្តិនានាសម្រាប់ជំរុញនិងលើកកម្ពស់ដល់ការបង្កើតនិងអភិវឌ្ឍនិរន្តរភាពទីក្រុង តាមរយៈការកសាងនូវគោលការណ៍មូលដ្ឋានគ្រឹះទូទៅ និងវិធានគតិយុត្តនានាដែលចាំបាច់សម្រាប់ប្រើប្រាស់ជាត្រីវិស័យ និងជាមគ្គុទេសក៏ដល់ការរៀបចំកសាងផែនការរៀបចំកសាងនិងអភិវឌ្ឍន៍ទីក្រុង និងទីប្រជុំជននានា ឱ្យមានភាពស្រស់បំព្រងអនុគ្រោះដល់ការរស់នៅរបស់មនុស្ស សត្វ និងជីវៈចម្រុះនានាផ្សេងៗទៀត ប្រកបដោយចីរភាព និងភាពសុខដុមរម្យនា

ខ. បង្កើតវិធានគតិយុត្តនានា សម្រាប់យកទៅអនុវត្តលើការចាត់ថ្នាក់និងកំណត់ទិសដៅនៃការប្រើប្រាស់ដីធ្លី កំណត់លក្ខន្តិកៈគតិយុត្តនៃប្រភេទដីនីមួយៗ ការកសាងនិងអភិវឌ្ឍន៍នយោបាយលំនៅដ្ឋាន ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ទំនាក់ទំនងរវាងការគ្រប់គ្រងការបំពុលគ្រប់ប្រភេទ និងមាត្រដ្ឋាននគរូបនីយកម្មនិងសំណង់ ដូចជា៖ ស្តង់ដារសាងសង់ ការរៀបចំសួនសាធារណៈ និងឯកជន ការគ្រប់គ្រងរចនាបថសំណង់អាគារ និងទេសភាព។ល។ តាមរយៈការចែងអំពីការប្រើប្រាស់សិទ្ធិ សេរីភាព ករណីយកិច្ច កាតព្វកិច្ច ការទទួលខុសត្រូវ និងបែបបទនីតិវិធីនានាដែលពាក់ព័ន្ធ

គ. សិក្សា វិភាគ និងស្នើវិធានការនានាដែលចាំបាច់សម្រាប់គាំពារ និងលើកទឹកចិត្តប្រជាជនឱ្យចូលរួមកែលម្អផ្នត់គំនិត របៀបរស់នៅ ការតាំងលំនៅដ្ឋាន និងទីអាជីវកម្មរបស់ខ្លួនសមស្របតាមគោលការណ៍ និងបទដ្ឋានគតិយុត្តថ្មី ស្តីពីការរៀបចំទីក្រុងប្រកបដោយ

និរន្តរភាព តាមរយៈការកំណត់សិទ្ធិ សេរីភាព កាតព្វកិច្ច និងករណីយកិច្ចជូនបុគ្គលដែលទទួលបានអាណត្តិពីរដ្ឋ ពីរាជរដ្ឋាភិបាល ឬពីរាស្ត្រ មន្ត្រីរាជការសាធារណៈ កងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ និងប្រជាជនគ្រប់រូប

ឃ. ស្នើនយោបាយហិរញ្ញប្បទាន និងយន្តការនានា ដែលចាំបាច់សម្រាប់គាំពារដល់ការកសាង និងអភិវឌ្ឍនិរន្តរភាពទីក្រុង

ង. បង្កើតវិធានគតិយុត្តនានាដែលចាំបាច់សម្រាប់លើកកម្ពស់ និងគាំពារដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ព្រមទាំងយន្តការនានាដែលចាំបាច់ សម្រាប់ដោះស្រាយផលប៉ះពាល់ដែលអាចកើតមានឡើង

ច. បង្កើតវិធានគតិយុត្តនានាដែលចាំបាច់សម្រាប់បង្កើត លើកកម្ពស់ និងគាំពារដល់ការដាក់ឱ្យអនុវត្តយ៉ាងទូលំទូលាយលើផ្ទៃប្រទេស នូវចរន្តសេដ្ឋកិច្ចបៃតង តាមរយៈការបង្កើតនិងអភិវឌ្ឍជាអាទិ៍ៈ នូវនយោបាយពន្ធដារមេត្រីបរិស្ថាន នយោបាយលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចផ្សេងទៀត ការជំរុញការសិក្សាស្រាវជ្រាវខាងបច្ចេកទេសនិងវិទ្យាសាស្ត្រ ការកំណត់អំពីរបៀបគ្រប់គ្រងការធ្វើអាជីវកម្មធនធានព្រៃឈើ ធនធានមច្ឆាជាតិ តីណជាតិ រ៉ែ និងធនធានធម្មជាតិផ្សេងៗទៀតជាដើម

ឆ. សិក្សា វិភាគ ប្រៀបធៀបបទប្បញ្ញត្តិពាក់ព័ន្ធនានា ដោយគូសបញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទនៃបញ្ហាប្រឈម យន្តការ និង/ឬវិធានការដែលចាំបាច់ដើម្បីដោះស្រាយ លប់បំបាត់ ឬបញ្ចៀសភាពស្រពិចស្រពិលផ្សេងៗ បញ្ហាបដិប្បញ្ញត្តិ បញ្ហាវិវាទយុត្តាធិការ បញ្ហាសង្កតភាពខាងគោលការណ៍ទូទៅ និង/ឬវិធានគតិយុត្តសម្រាប់ធានាប្រសិទ្ធភាពអនុវត្តជាដើម

ជ. សិក្សា វិភាគ ប្រៀបធៀបនិងចង្អុលបង្ហាញច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលត្រូវធ្វើវិសោធនកម្ម ឬនិរាករណ៍ អនុលោមតាមការចាំបាច់

ឈ. រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួន ជូនក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ព្រមទាំង កំណត់បង្ហាញ និងសេចក្តីថ្លែងហេតុនានា។

៣.ចូលរួមប្រជុំ និងវេទិកាផ្សេងៗ តាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

ដ. បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន។

**ប្រការ ៧.-**

ក្រុមការងារគ្រប់គ្រងសំណល់ និងការបំពុល ជាសេនាធិការនៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោក **ឌ្រិន សុខា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន | ប្រធាន |
| ២- លោក **ខា ស៊ីណា** | ប្រធាននាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣- លោក | **ថុល ចាន់ថន** | ប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ | សមាជិក |
| ៤- លោក | **ឌី គីដែន** | ប្រធាននាយកដ្ឋានគ្រប់គ្រងសំណល់រឹង | សមាជិក |
| ៥- លោក | **ផិត ពេឆរ៉ា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រង សារធាតុគ្រោះថ្នាក់ | សមាជិក |
| ៦- លោក | **សារុន សំបូរ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងសំណល់រឹង | សមាជិក |
| ៧- លោក | **តិន វ៉ាឌី** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពទឹក | សមាជិក |
| ៨- តំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ | | | សមាជិកអញ្ជើញ |
| ៩- អ្នកជំនាញការជាតិ និង/ឬអន្តរជាតិ | | | សមាជិកអញ្ជើញ |

ប្រធានក្រុមការងារបច្ចេកទេស ឬប្រធានក្រុមការងារគ្រប់គ្រងសំណល់និងការបំពុល អាចស្នើសុំបន្ថែមសមាជិករបស់ខ្លួន តាមការចាំបាច់។ ការតែងតាំងនេះត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ ៨.-**

ក្រុមការងារគ្រប់គ្រងសំណល់និងការបំពុល មានតួនាទី និងភារកិច្ចជាសារវន្តដូចខាងក្រោម៖

ក. សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគប្រៀបធៀបច្បាប់ បទដ្ឋានគតិយុត្តជាធរមាន និងបទពិសោធន៍ល្អៗដែលមាន ដើម្បីស្នើចេញនូវខ្លឹមសារនៃសេចក្តីព្រាងបទប្បញ្ញត្តិនានាសម្រាប់ជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំណល់ និងការបំពុលគ្រប់ប្រភេទដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរាប់បញ្ចូលជាអាទិ៍៖ នូវដែនគោក ដែនសមុទ្រ ទន្លេ ស្ទឹង ប្រភពទឹកផ្សេងៗ ទីក្រុង ទីប្រជុំជន រោងចក្រ សិប្បកម្ម សហគ្រាស និងទីសាធារណៈនានាដទៃទៀត សំដៅធ្វើយ៉ាងណាកសាងបាននូវបរិស្ថានរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតដ៏ស្រស់បំព្រងពេញបរិបូណ៌ដោយសុវត្ថិភាព សម្រាប់មនុស្ស និងជីវៈចម្រុះនានារស់នៅ ប្រកបដោយផាសុកភាព និងភាពសុខដុមរម្យនាជានិរន្តន៍នឹងគ្នា

ខ. បង្កើតយន្តការនិងវិធានគតិយុត្តនានា ដែលចាំបាច់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំណលរឹង សំណល់រាវ សារធាតុគ្រោះថ្នាក់ ការបញ្ចេញឧស្ម័ននានាទៅក្នុងបរិយាកាស ការគ្រប់គ្រងគុណភាពបរិយាកាសក្នុងអាគារ ការគ្រប់គ្រងសម្លេងនិងរំញ័រ ការកំណត់ស្តង់ដារនិងមូលដ្ឋានបច្ចេកទេស សម្រាប់អនុវត្តចំពោះការផលិត ការបំពាក់ ការធ្វើអាជីវកម្ម ការថែទាំ ឬការកែច្នៃ ការគ្រប់គ្រង តាមដាននិងត្រួតពិនិត្យនូវបញ្ហាដូចខាងក្រោម៖ ប្រព័ន្ធបង្ហូរឬដោះទឹកភ្លៀង ការផលិត ការប្រមូល ការស្តុក ការលើកដាក់ ការដឹកជញ្ជូន ការតំឡើង ការបំពាក់ ការប្រើប្រាស់ ការធ្វើអាជីវកម្មតាមគ្រប់រូបភាព ការកែច្នៃគ្រប់ប្រភេទ និងការចាត់ចែងសំណល់ វត្ថុនានា និង/ឬសារធាតុទាំងឡាយខាងលើ

គ. សិក្សា វិភាគនិងស្នើវិធានការនានាដែលចាំបាច់សម្រាប់គាំពារនិងលើកទឹកចិត្តប្រជាជនឱ្យចូលរួមកែលម្អផ្នត់គំនិត និងរបៀបរស់នៅឱ្យបានសមស្របតាមគោលការណ៍ និងបទដ្ឋានគតិយុត្តថ្មីស្តីពីការគ្រប់គ្រងសំណល់និងការបំពុល តាមរយៈការកំណត់សិទ្ធិ សេរីភាព

កាតព្វកិច្ច និងករណីយកិច្ចជូនបុគ្គលដែលទទួលបានអាណត្តិពីរដ្ឋ ពីរាជរដ្ឋាភិបាល ឬពីរាស្ត្រ មន្ត្រីរាជការសាធារណៈ កងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ ប្រជាជនគ្រប់រូប និងបុគ្គលដទៃទៀតដែលបង្កើតដោយច្បាប់

ឃ.បង្កើតមូលដ្ឋានគ្រឹះនៃការកសាង និងអភិវឌ្ឍយន្តការនានា ដែលចាំបាច់សម្រាប់គាំពារដល់ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ និងការបំពុល ដោយរួមបញ្ចូលទាំងការបង្កើតប្រព័ន្ធលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ការទូទាត់សេវាបរិស្ថាន ការបង្កើតនយោបាយពន្ធដារ ប្រព័ន្ធវិនិយោគ ការគ្រប់គ្រង និងតម្រង់ទិសដំណើរវិវត្តន៍នៃចរន្តសេដ្ឋកិច្ចទីផ្សារ ដើម្បីជាប្រយោជន៍ដល់ការលើកកម្ពស់ការអនុវត្តនយោបាយកាត់បន្ថយ ឬលុបបំបាត់ការបំពុលបរិស្ថានជាដើម

ង. បង្កើតវិធានគតិយុត្តនានាដែលចាំបាច់សម្រាប់បង្កើត លើកកម្ពស់និងគាំពារដល់ការដាក់ឱ្យអនុវត្តយ៉ាងទូលំទូលាយលើផ្ទៃប្រទេស នូវការសិក្សា ស្រាវជ្រាវ និងចរាចរណ៍ផលិតផលបច្ចេកវិជ្ជា និងវិធីសាស្ត្រនានាដែលគាំពារដល់ចំណុចទាំងអស់ខាងលើ

ច. សិក្សា វិភាគ ប្រៀបធៀបបទប្បញ្ញត្តិពាក់ព័ន្ធនានា ដោយគូសបញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទនៃបញ្ហាប្រឈម យន្តការ និង/ឬវិធានការដែលចាំបាច់ ដើម្បីដោះស្រាយ លុបបំបាត់ ឬបញ្ចៀសភាពស្រពិចស្រពិលផ្សេងៗ បញ្ហាបដិប្បញ្ញត្តិ បញ្ហាវិវាទយុត្តាធិការ បញ្ហាសង្គតភាពខាងគោលការណ៍ទូទៅ និង/ឬវិធានគតិយុត្តសម្រាប់ធានាប្រសិទ្ធភាពអនុវត្តជាដើម

ឆ. សិក្សា វិភាគ ប្រៀបធៀប និងចង្អុលបង្ហាញច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលត្រូវធ្វើវិសោធនកម្ម ឬនិរាករណ៍ អនុលោមតាមការចាំបាច់

ជ. រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួន ជូនក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ព្រមទាំងកំណត់បង្ហាញ និងសេចក្តីថ្លែងហេតុនានា

ឈ.ចូលរួមប្រជុំ និងវេទិកាផ្សេងៗ តាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

ញ.បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន។

**ប្រការ ៩.-**

ក្រុមការងារអភិរក្សរុក្ខឧទ្យាន សត្វព្រៃ និងជីវៈចម្រុះ ជាសេនាធិការនៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោក **មាស សុផល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | ប្រធាន |
| ២- លោក **គង់ គីមស្រេង** | ប្រធាននាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោក | អនុប្រធាន |

៣- លោក **ឃិន ម៉េងឃាង** ប្រធាននាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ សមាជិក

៤- តំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ សមាជិកអញ្ជើញ

៥- អ្នកជំនាញការជាតិ និង/ឬអន្តរជាតិ សមាជិកអញ្ជើញ

ប្រធានក្រុមការងារបច្ចេកទេស ឬប្រធានក្រុមការងារអភិរក្សរុក្ខឧទ្យាន សត្វព្រៃ និងជីវៈចម្រុះ អាចស្នើសុំបន្ថែមសមាជិករបស់ខ្លួន តាមការចាំបាច់។ ការតែងតាំងនេះ ត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ ១០.-**

ក្រុមការងារអភិរក្សរុក្ខឧទ្យាន សត្វព្រៃ និងជីវៈចម្រុះ មានតួនាទី និងភារកិច្ចជាសារវ័ន្តដូចខាងក្រោម៖

ក. សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគប្រៀបធៀបច្បាប់ បទដ្ឋានគតិយុត្តជាធរមាន និងបទពិសោធន៍ល្អៗដែលមាន ដើម្បីស្នើចេញនូវខ្លឹមសារនៃសេចក្តីព្រាងបទប្បញ្ញត្តិនានាសម្រាប់ជំរុញនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងរុក្ខឧទ្យាន និងឧទ្យានក្នុងដែនគោកទាំងអស់ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរាប់បញ្ចូលជាអាទិ៍៖ ឧទ្យានជាតិ ដែនជម្រក ព្រៃបម្រុងទុក និងតំបន់ការពារដែលកំណត់ក្នុងច្បាប់បរិស្ថាន និងច្បាប់ពាក់ព័ន្ធនានាជាធរមាននាពេលបច្ចុប្បន្ន និងតំបន់ផ្សេងទៀតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចាំបាច់សម្រាប់លើកស្ទួយការស្តារ និងអភិរក្សជីវៈចម្រុះ ធនធានព្រៃឈើ ក៏ដូចជាផលនិងអនុផលព្រៃឈើនានា។

ខ. បង្កើតយន្តការ និងវិធានគតិយុត្តនានា ដែលចាំបាច់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង បង្ការ និងទប់ស្កាត់រាល់សកម្មភាពនានា ដែលអាចនាំដល់ការបំផ្លាញព្រៃឈើ សត្វព្រៃ ផល និងអនុផលព្រៃឈើនានា ព្រមទាំងជីវៈចម្រុះផ្សេងៗ សំដៅធានាបាននូវការកសាងសន្និធិអេកូឡូស៊ីដ៏សំបូរបែបទុកជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ ការលើកកម្ពស់ប្រពៃណីវប្បធម៌ និងអរិយធម៌របស់ជាតិ ការអភិវឌ្ឍន៍អេកូទេសចរណ៍ ការធានាបាននូវនិរន្តរភាពនៃធនធានធម្មជាតិ ដែលជាប្រភពទុនមិនចេះរីងស្ងួតសម្រាប់មនុស្សជំនាន់ក្រោយ តាមរយៈការដាក់បញ្ចូលជាអាទិ៍នូវបទប្បញ្ញត្តិសម្រាប់ជំរុញនិងលើកស្ទួយសកម្មភាពដូចខាងក្រោម៖

- អភិរក្សឧទ្យាន សត្វព្រៃ ជម្រកសត្វព្រៃនិងជីវៈចម្រុះនានា និងការលើកកម្ពស់ការអប់រំមហាជន ការសិក្សាស្រាវជ្រាវលើគ្រប់វិស័យ និងការសហការគ្នារវាងសហគមន៍អ្នកសិក្សា ស្រាវជ្រាវ សហគមន៍អ្នកទេសចរណ៍ ឧទ្យានុរក្ស វិនិយោគិនជាតិ-អន្តរជាតិដែលស្រឡាញ់ការអភិរក្ស និងការទាញយកប្រយោជន៍ប្រកបដោយនិរន្តរភាពពីធនធានខាងលើ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ
- កិច្ចការអភិរក្សនិងការរស់នៅដោយចីរភាព

- លើកស្ទួយកិច្ចការអភិរក្សព្រៃឈើ សត្វព្រៃ ជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី(ជម្រក) តាមរយៈការដាក់បញ្ចូលនូវយន្តការវិស្វកម្មហិរញ្ញប្បទានថ្មីៗ ដើម្បីជាប្រយោជន៍ដល់ការបង្ក និងបង្កើតនូវកាលានុវត្តភាពធុរកិច្ច និងឱកាសការងារជាច្រើនជូនជាតិ និងប្រជាជន ក៏ដូចជាការបង្កឱកាសដល់ការដាក់ឱ្យអនុវត្តសេវាបម្រើតាមឧទ្យាននានា (ឧទាហរណ៍ៈ សេវាមគ្គុទេសក៏ សួនសត្វ សួនផ្កា សួនរុក្ខជាតិចម្រុះ សារមន្ទីរ ធនាគារ ឬមណ្ឌលអភិរក្សផ្សេងៗ) ការគ្រប់គ្រងឱ្យបានពិតប្រាកដ និងហ្មត់ចត់ចំពោះសកម្មភាពកាប់ ការចាប់ ការប្រមាញ់ ការជួញដូរ ការប្រើប្រាស់ ឬអាស្រ័យផលតាមគ្រប់រូបភាព លើផលនិងអនុផលព្រៃឈើគ្រប់ប្រភេទ (ដោយរាប់បញ្ចូលបញ្ហាអាជ្ញាប័ណ្ណ និងការដាក់ទណ្ឌកម្មជាដើម) ការគ្រប់គ្រងហានិភ័យនិងគ្រោះមហន្តរាយធម្មជាតិ
- ការល្បាត ការតាមដាន ការអង្កេត ការស្រាវជ្រាវ ការទប់ស្កាត់បទល្មើសនានា ព្រមទាំងការសហការឆ្លងដែន និងនីតិវិធីតុលាការជាដើម (ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីសមត្ថកិច្ច អំណាច សិទ្ធិ បុព្វសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវព្រមទាំងបែបបទនិងនីតិវិធីពាក់ព័ន្ធដែលត្រូវយកមកអនុវត្ត)
- ការបង្កើតនិងផ្តល់ជូននូវសេវាថែទាំ ព្យាបាលនិងសង្គ្រោះសត្វព្រៃ
- ការស្តារព្រៃ និងប្រព័ន្ធអេកូឡូស៊ីដែលវិចវិល ឬបាត់បង់តាមរយៈការដាក់ចេញនូវគោលការណ៍និងវិធាននានាដែលចាំបាច់សម្រាប់លើកស្ទួយដល់ការបង្កើតកម្មវិធីយុទ្ធនាការ ឬសកម្មភាពប្រហាក់ប្រហែលនានាផ្សេងទៀតដែលបម្រើដល់គោលដៅខាងដើម ដោយចង្អុលបង្ហាញពីលទ្ធភាព វិធី របៀប និងបច្ចេកទេសនៃការធ្វើការប្រព័ន្ធហិរញ្ញប្បទាន នយោបាយលើកទឹកចិត្ត ឬគាំពារផ្សេងៗ ព្រមទាំងរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងនានាដែលសមស្រប
- ការធ្វើការដាក់បញ្ចូលនូវយន្តការគ្រប់គ្រងធនធានធម្មជាតិទាំងអស់ខាងលើ ស្របតាមទិសដៅនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់ជាតិ ក៏ដូចជានយោបាយសមាហរណកម្មទៅក្នុងសហគមន៍អន្តរជាតិនានា ដោយធ្វើការតម្កល់ឧត្តមប្រយោជន៍ជាតិជាធំ

គ. សិក្សា វិភាគនិងស្នើវិធានការនានា ដែលចាំបាច់សម្រាប់គាំពារ និងលើកទឹកចិត្តប្រជាជនឱ្យចូលរួមកែលម្អផ្នត់គំនិត និងរបៀបរស់នៅឱ្យបានសមស្របតាមគោលការណ៍ និងបទដ្ឋានគតិយុត្តថ្មីៗ តាមរយៈការកំណត់សិទ្ធិ សេរីភាព កាតព្វកិច្ច និងករណីយកិច្ចជូនបុគ្គលដែលទទួលបានអាណត្តិពីរដ្ឋ ពីរាជរដ្ឋាភិបាល ឬពីរាស្ត្រ មន្ត្រីរាជការសាធារណៈ កងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ ប្រជាជនគ្រប់រូប និងបុគ្គលដទៃទៀតដែលបង្កើតដោយច្បាប់

ឃ.សិក្សា វិភាគ ប្រៀបធៀបបទប្បញ្ញត្តិពាក់ព័ន្ធនានា ដោយគូសបញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទនៃបញ្ហាប្រឈម យន្តការ និង/ឬវិធានការដែលចាំបាច់ ដើម្បីដោះស្រាយ លុបបំបាត់ ឬបញ្ចៀសភាពស្រពិចស្រពិលផ្សេងៗ បញ្ហាបដិប្បញ្ញត្តិ បញ្ហាវិវាទយុត្តាធិការ បញ្ហាសង្គតភាពខាងគោលការណ៍ទូទៅ និង/ឬវិធានគតិយុត្តសម្រាប់ធានាប្រសិទ្ធភាពអនុវត្តជាដើម

ច. សិក្សា វិភាគ ប្រៀបធៀប និងចង្អុលបង្ហាញច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលត្រូវធ្វើវិសោធនកម្ម ឬនិរាករណ៍ អនុលោមតាមការចាំបាច់

ឆ. រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួន ជូនក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ព្រមទាំងកំណត់បង្ហាញ និងសេចក្តីថ្លែងហេតុនានា

ជ. ចូលរួមប្រជុំ និងវេទិកាផ្សេងៗ តាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

ឈ.បំពេញភារកិច្ចផ្សេងទៀត តាមការចាំបាច់ ឬតាមការចាត់តាំងរបស់ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន។

**ប្រការ ១១.-**

ក្រុមការងារអភិរក្សបេតិកភណ្ឌនិងឧទ្យានធម្មជាតិ ជាសេនាធិការនៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោក | **សេខ សោភ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ប្រធាន |
| ២- លោក | **នេត នាថ** | ប្រធាននាយកដ្ឋានតំបន់បេតិកភណ្ឌ | អនុប្រធាន |
| ៣- តំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ | | | សមាជិកអញ្ជើញ |
| ៤- អ្នកជំនាញការជាតិ និង/ឬអន្តរជាតិ | | | សមាជិកអញ្ជើញ |

ប្រធានក្រុមការងារបច្ចេកទេស ឬប្រធានក្រុមការងារអភិរក្សបេតិកភណ្ឌនិងឧទ្យានធម្មជាតិ អាចស្នើសុំបន្ថែមសមាជិករបស់ខ្លួន តាមការចាំបាច់។ ការតែងតាំងនេះត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ ១២.-**

ក្រុមការងារអភិរក្សឧទ្យានបេតិកភណ្ឌនិងធម្មជាតិ មានតួនាទី និងភារកិច្ចជាសារវ័ន្ត ដូចខាងក្រោម៖

ក. សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគប្រៀបធៀបច្បាប់ បទដ្ឋានគតិយុត្តជាធរមាន និងបទពិសោធន៍ល្អៗដែលមាន ដើម្បីស្នើចេញនូវខ្លឹមសារនៃសេចក្តីព្រាងបទប្បញ្ញត្តិនានា សម្រាប់ជំរុញនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងបូរាណដ្ឋាន កេរដំណែលប្រវត្តិសាស្ត្រ បូរាណវត្ថុនានាដែលមានប្រយោជន៍ដល់ការលើកកម្ពស់ ការយល់ដឹងពីប្រវត្តិសាស្ត្រ ដំណើរវិវត្តន៍នៃភូគព្ភសាស្ត្រ ប្រពៃណី និងវប្បធម៌របស់ជាតិ និងជនជាតិនានាផ្សេងទៀត មានជាអាទិ៍៖ ប្រាសាទ ផ្នូរឬទីស្មសានបូរាណ សិលាចារឹក ចម្លាក់ សង្ហារឹមចលនៈ ឬអចលនៈទ្រព្យផ្សេងៗ រួមទាំង នាវាឬក្រុងបូរាណដែលកប់ក្នុងសមុទ្រ ឬក្រោមដីជាដើម ដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ខ.បង្កើតយន្តការនិងវិធានគតិយុត្តនានា ដែលចាំបាច់សម្រាប់លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌និងធម្មជាតិ ដោយកំណត់អំពីគោលការណ៍

វិធានគតិយុត្ត បែបបទនិងនីតិវិធីនានាដែលជួយជាប្រយោជន៍ដល់ការអភិរក្ស ការជួសជុលថែទាំ ការលើកកម្ពស់ការផ្សព្វផ្សាយ ការសិក្សាស្រាវជ្រាវ និងការបង្កបង្កើតឱកាសធុរកិច្ច និងកាលានុវត្តភាពការងារនានាដែលបម្រើឱ្យគោលដៅរួមជាសារវន្តតែមួយ ស្របតាមទ្រឹស្តី "អភិរក្ស ដើម្បីអភិវឌ្ឍន៍ -អភិវឌ្ឍន៍ដើម្បីអភិរក្ស" ដូចជាការដាក់បញ្ចូលនូវយន្តការនានាដែលនាំដល់ការការអភិរក្សនិងការដាក់តាំងបង្ហាញអប់រំផ្សព្វផ្សាយ (រួមមាន សារមន្ទីររដ្ឋ ឯកជន និងចម្រុះរដ្ឋជាដើម) ការផលិតខ្សែភាពយន្ត ឯកសារនានាតាមគ្រប់រូបភាព ការបំផុសទេសចរណ៍វប្បធម៌និងធម្មជាតិ ការបំផុសចលនាសហគមន៍ ការលើកទឹកចិត្តឱ្យអភិវឌ្ឍហិរញ្ញប្បទានថ្មីៗ (មូលនិធិ សមាគមន៍ ក្រុមហ៊ុនចម្រុះ កិច្ចសហការជាអន្តរជាតិរវាងវិទ្យាស្ថានស្រាវជ្រាវនានា ការសហការរវាងវិនិយោគិននិងវិទ្យាស្ថានស្រាវជ្រាវ ឬមូលនិធិរដ្ឋ ឬឯកជនជាអន្តរជាតិជាដើម)

គ.សិក្សា វិភាគនិងស្នើវិធានការនានាដែលចាំបាច់សម្រាប់គាំពារនិងលើកទឹកចិត្តប្រជាជនឱ្យចូលរួមកែលម្អផ្នត់គំនិត និងរបៀបរស់នៅឱ្យបានសមស្របតាមគោលការណ៍ និងបទដ្ឋានគតិយុត្តថ្មីស្តីពីការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌និងធម្មជាតិ តាមរយៈការកំណត់សិទ្ធិ សេរីភាព កាតព្វកិច្ច និងករណីយកិច្ចជូនបុគ្គលដែលទទួលបានអាណត្តិពីរាជរដ្ឋាភិបាល ឬពីរាស្ត្រ មន្ត្រីរាជការសាធារណៈ កងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ ប្រជាជនគ្រប់រូប និងបុគ្គលដទៃទៀតដែលបង្កើតដោយច្បាប់ ព្រមគ្នាជាមួយនឹងការបង្កើតនយោបាយលើកទឹកចិត្តនិង/ឬដាក់ទណ្ឌកម្មដ៏សំបូរបែប ជាអាទិ៍៖ អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ការផ្តល់នយោបាយលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច នយោបាយពន្ធដារ ការសម្រួលបែបបទ-នីតិវិធីពាក់ព័ន្ធ ការគ្រប់គ្រង បង្កា ទប់ស្កាត់ និងបង្រ្កាបបទល្មើសជួញដូរបេតិកភណ្ឌ ការធ្វើការតាមដាន អង្កេត ស្រាវជ្រាវ នីតិវិធីចំពោះមុខតុលាការ និងកិច្ចសហការជាអន្តរជាតិជាដើម)

ឃ.បង្កើតមូលដ្ឋានគ្រឹះនៃការកសាង និងអភិវឌ្ឍយន្តការនានាដែលចាំបាច់សម្រាប់គាំពារដល់ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងធម្មជាតិ ដោយគិតគូរលើគ្រប់បញ្ហា និងទិដ្ឋភាពនានាដែលពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលពិសេសផ្សារភ្ជាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ ជាមួយនឹងការអភិរក្សធនធានធម្មជាតិ (ព្រៃឈើ ផលនិងអនុផលព្រៃឈើ និងជីវៈចម្រុះ) អនុលោមតាមនយោបាយវិមជ្ឈការ វិសហមជ្ឈការ ក៏ដូចជាសមាហរណកម្មទៅក្នុងសហគមន៍អន្តរជាតិនានា ដោយកំណត់ឱ្យបានច្បាស់លាស់អំពីតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ

ង. សិក្សា វិភាគ ប្រៀបធៀបបទប្បញ្ញត្តិពាក់ព័ន្ធនានា ដោយគូសបញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទនៃបញ្ហាប្រឈម យន្តការ និង/ឬវិធានការដែលចាំបាច់ដើម្បីដោះស្រាយ លុបបំបាត់ ឬបញ្ចៀសភាពស្រពិចស្រពិលផ្សេងៗ បញ្ហាបដិប្បញ្ញត្តិ បញ្ហាវិវាទយុត្តាធិការ បញ្ហាសង្កតភាពខាងគោលការណ៍ទូទៅ និង/ឬវិធានគតិយុត្តសម្រាប់ធានាប្រសិទ្ធភាពអនុវត្តជាដើម

ច. សិក្សា វិភាគ ប្រៀបធៀប និងចង្អុលបង្ហាញច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលត្រូវធ្វើវិសោធនកម្ម ឬនិរាករណ៍ អនុលោមតាមការចាំបាច់

ឆ. រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួនជូនក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ព្រមទាំងកំណត់បង្ហាញ និងសេចក្តីថ្លែងហេតុនានា

ជ. ចូលរួមប្រជុំ និងវេទិកាផ្សេងៗ តាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

ឈ.បំពេញការកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន។

**ប្រការ ១៣.-**

ក្រុមការងារគ្រប់គ្រងតំបន់ដីសើម និងអភិរក្សជីវៈចម្រុះទឹកសាបនិងទឹកប្រៃ ជាសេនាធិការនៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោក | **គីម ឈុន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | ប្រធាន |
| ២- លោក | **ស្រី ស៊ុនលាន** | ប្រធាននាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប | អនុប្រធាន |
| ៣- លោក | **ថៃ ចាន់ថា** | ប្រធាននាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ | សមាជិក |
| ៤- តំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ | | | សមាជិកអញ្ជើញ |
| ៥- អ្នកជំនាញការជាតិ និង/ឬអន្តរជាតិ | | | សមាជិកអញ្ជើញ |

ប្រធានក្រុមការងារបច្ចេកទេស ឬក្រុមការងារគ្រប់គ្រងតំបន់ដីសើម និងអភិរក្សជីវៈចម្រុះទឹកសាបនិងទឹកប្រៃ អាចស្នើសុំបន្ថែមសមាជិករបស់ខ្លួន តាមការចាំបាច់។ ការតែងតាំងនេះត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ ១៤.-**

ក្រុមការងារគ្រប់គ្រងតំបន់ដីសើម និងអភិរក្សជីវៈចម្រុះទឹកសាបនិងទឹកប្រៃ មានតួនាទី និងភារកិច្ចជាសារវ័ន្តដូចខាងក្រោម៖

ក.សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគប្រៀបធៀបច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីស្នើចេញនូវខ្លឹមសារនៃសេចក្តីព្រាងបទប្បញ្ញត្តិនានសម្រាប់ជំរុញនិងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ដីសើម និងអភិរក្សជីវៈចម្រុះទឹកសាបនិងទឹកប្រៃ ក៏ដូចជាស្តារនិង/ឬពង្រីកបន្ថែមនូវទំហំផ្ទៃនៃឧទ្យានសមុទ្រ ឋបនីយជីវមណ្ឌល តំបន់រ៉ាំសារ និងតំបន់ថ្មីៗផ្សេងទៀតដែលមានគុណវុឌ្ឍន៍គ្រប់គ្រាន់សម្រាប់ចាត់ថ្នាក់ជាតំបន់ការពារប្រភេទថ្មី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរាប់បញ្ចូលជាអាទិ៍៖ ដែនសមុទ្រ ទន្លេ ស្ទឹង ព្រែក បឹងបួរ និងប្រភពទឹកផ្សេងៗទៀត ក៏ដូចជាទីក្រុង និងទីប្រជុំជនផ្សេងៗ សំដៅធ្វើយ៉ាងណារក្សាបាននូវតុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី និងភាពសំបូរបែបនៃជីវៈចម្រុះនានា រួមមានរុក្ខជាតិ តិណជាតិ វារីជាតិ សត្វស្លាប មច្ឆាជាតិ សត្វល្អិត និងការរស់

ផ្សេងៗ ដើម្បីជាមូលដ្ឋាននៃការរស់នៅប្រកបដោយចីរភាព ពេញបរិបូណ៌ដោយសុវត្ថិភាព ភាពស្រស់បំព្រង ផាសុកភាព និងភាពសុខដុមរមនាជានិរន្តន៍រវាងមនុស្ស សត្វ និងភាវរស់នានាទាំងសម្រាប់បច្ចុប្បន្នកាលនិងអនាគតកាល

ខ.បង្កើតយន្តការនិងវិធានគតិយុត្តនានា ដែលចាំបាច់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង បង្ការនិងទប់ស្កាត់រាល់សកម្មភាពនានាដែលអាចនាំដល់ការធ្វើឱ្យវិចវិល ថយចុះ ឬការបាត់បង់ជានិរន្តន៍នូវបរិមាណ និង/ឬពូជជីវៈចម្រុះផ្សេងៗ តាមរយៈការជំរុញឱ្យមានជាអាទិ៍ ការកសាងនិងអភិវឌ្ឍនូវសន្និធិជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីដ៏សំបូរបែបដោយរាប់បញ្ចូលទាំងក្នុងទីក្រុង និងទីប្រជុំជនទូទៅ ដើម្បីទុកជាប្រយោជន៍ដល់ការអប់រំផ្សព្វផ្សាយ សិក្សាស្រាវជ្រាវ ការលើកកម្ពស់ប្រពៃណីវប្បធម៌និងអរិយធម៌របស់ជាតិ ការអភិវឌ្ឍន៍អេកូទេសចរណ៍ ការធានាបាននូវនិរន្តរភាពនៃធនធានធម្មជាតិ ដែលជាប្រភពទុនមិនចេះរីងស្ងួតសម្រាប់មនុស្សជំនាន់ក្រោយ ជាពិសេសការសិក្សាពីលទ្ធភាពក្នុងការបង្កើតនូវបទប្បញ្ញត្តិសម្រាប់ជំរុញ និងលើកស្ទួយសកម្មភាពដូចខាងក្រោម៖

- កិច្ចការអភិរក្សនិងការរស់នៅដោយចីរភាព
- ការគ្រប់គ្រងការអាស្រ័យផលក្នុងដែនសមុទ្រ ទន្លេ ដៃទន្លេ ស្ទឹង បឹងបួរ ព្រៃកអូរ តំបន់ដីសើមនានា និងប្រភពផ្សេងៗទៀតនៃជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីតាមរយៈការដាក់បញ្ចូលនូវយន្តការគ្រប់គ្រងទិន្នន័យ ចំណាត់ថ្នាក់ជីវៈចម្រុះ វិស្វកម្មហិរញ្ញប្បទានថ្មីៗ ការចូលរួមរៀបចំមូលដ្ឋានគតិយុត្តសម្រាប់កសាងផែនទីប្រើប្រាស់ដី ការចលនាសហគមន៍ ការលើកកម្ពស់តួនាទីរបស់វិស័យឯកជន និងតួនាទីរបស់រដ្ឋបាលថ្នាក់ជាតិ និង/ឬថ្នាក់មូលដ្ឋានក្នុងនាមជានិយ័តករ ឬភ្នាក់ងារសេដ្ឋកិច្ចដ៏សកម្ម
- ការកំណត់លក្ខខណ្ឌ បែបបទ និងនីតិវិធីនានាសម្រាប់គ្រប់គ្រងសកម្មភាពអាជីវកម្ម និង/ឬអាស្រ័យផលតាមរូបភាពផ្សេងៗទៀត លើធនធានទឹក (ទឹកសាប ទឹកប្រៃ តំបន់ទ្រនាប់ និងតំបន់ដីសើម) និងធនធានជីវៈចម្រុះនានាដោយរាប់បញ្ចូលទាំងការយកទឹកទៅប្រើប្រាស់សម្រាប់បម្រើគោលដៅសេដ្ឋកិច្ចឬកសិកម្ម ការអាស្រ័យផលជាលក្ខណៈគ្រួសារ ការតាំងទីលំនៅលើទឹក ឬតាមមាត់ទឹក ឬតាមតំបន់ត្រូវការពារ ការគ្រប់គ្រងសារមន្ទីរធនធានជីវៈចម្រុះ (ទឹកសាប ទឹកប្រៃ) សារមន្ទីរសំណាក ផែរនេសាទ ផែរកំសាន្ត ការចរាចរណ៍នាវាគ្រប់ប្រភេទ ការកំណត់ទំហំ បរិមាណ អាយុ និង/ឬប្រភេទជីវៈចម្រុះដែលអាចទាញយកផលមកអាស្រ័យបាន វិធីចាប់ ឧបករណ៍ ពេលវេលា សិទ្ធិ សេរីភាព កាតព្វកិច្ច ការទទួលខុសត្រូវ និងការរឹតត្បិតនានា។ល។)
- ការលើកកម្ពស់ចលនាបង្កើតអាងស្តុកទឹកបម្រុង ដោយពិចារណាអំពីឥទ្ធិពលនៃលក្ខខណ្ឌអាកាសធាតុ ការវិវត្តន៍នៃស្ថានភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រជាដើម ដើម្បីជាប្រយោជន៍ដល់សន្តិសុខ និងសុវត្ថិភាពនៃធនធានទឹក ការគ្រប់គ្រង

គុណភាពទឹក និងគុណភាពដី (សម្រាប់តម្រូវការនៃការរស់នៅប្រចាំថ្ងៃ កសិកម្ម សេដ្ឋកិច្ច និងការអភិរក្សជីវៈចម្រុះនាពេលអនាគត)

- បង្កើតវិធានគតិយុត្តដែលចាំបាច់សម្រាប់គ្រប់គ្រង ល្បាត តាមដាន ត្រួតពិនិត្យ ហាមឃាត់ និង/ឬទប់ស្កាត់ការនាំចូល ការស្តុក ការលក់ដូរ ការចែកចាយ ការដេញថ្លៃ (សម្រាប់តម្រូវការក្នុងភូមិ-ស្រុក រាជធានី-ខេត្ត ឬ អន្តរជាតិ) ឬការប្រើប្រាស់ ឬអាស្រ័យផល ឬការរីកសាយភាយតាមគ្រប់រូបភាពនូវការប្រើប្រាស់ផលិតផលផ្សេងៗដែលអាចគំរាមកំហែង ឬធ្វើឱ្យបាត់បង់ ឬផុតពូជ ឬប៉ះពាល់ដល់ជីវៈចម្រុះក្នុងស្រុក ជាអាទិ៍ៈសត្វចិញ្ចឹមលំហែកំសាន្ត ឬលម្អ រុក្ខជាតិ ផ្កា វល្លិ៍សម្រាប់តាំងលម្អ ថ្នាំសម្លាប់សត្វល្អិត ថ្នាំបំប៉ន ថ្នាំគីមីនិង/ឬជីគ្រប់ប្រភេទដែលត្រូវប្រើប្រាស់លើដី ទឹកលើសត្វ លើរុក្ខជាតិ និងពូជជីវៈចម្រុះដែលរងការកែច្នៃសរីរាង្គ ឬពូជនាំចូលពីបរទេស (ជីវៈចម្រុះនិងជីវសុវត្ថិភាព)
- ដាក់បញ្ចូលស្មារតីនៃនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់ជាតិ ក៏ដូចជានយោបាយសមាហរណកម្មទៅក្នុងសហគមន៍អន្តរជាតិនានា ទៅក្នុងយន្តការអនុវត្តន៍ច្បាប់ ដោយធ្វើការតម្កល់ឧត្តមប្រយោជន៍ជាតិជាធំ

គ. សិក្សា វិភាគ និងស្នើវិធានការនានាដែលចាំបាច់សម្រាប់គាំពារ និងលើកទឹកចិត្តប្រជាជនឱ្យចូលរួមកែប្រែផ្នត់គំនិត និងរបៀបរស់នៅឱ្យបានសមស្របតាមគោលការណ៍ និងបទដ្ឋានគតិយុត្តថ្មី តាមរយៈកិច្ចការជាច្រើន ជាអាទិ៍ៈ

- ការបង្កើតនយោបាយអប់រំ នយោបាយលើកទឹកចិត្ត និង/ឬគាំពារផ្សេងៗ (កម្មវិធីសិក្សា ការផ្សព្វផ្សាយ ការបោះពុម្ពផ្សាយ នយោបាយពន្ធដារ ការប្រកួតប្រជែងរង្វាន់ ឧបត្ថម្ភធន មូលនិធិ ...) ព្រមទាំងយន្តការធានាប្រសិទ្ធភាព អនុវត្តដែលចាំបាច់
- ការកំណត់សិទ្ធិ សេរីភាព កាតព្វកិច្ច និងករណីយកិច្ចជូនបុគ្គលដែលទទួលបានអាណត្តិពីរដ្ឋ ពីរាជរដ្ឋាភិបាលឬពីរាស្ត្រ មន្ត្រីរាជការសាធារណៈ កងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ ប្រជាជនគ្រប់រូប និងនីតិបុគ្គលផ្សេងៗ

ឃ.សិក្សា វិភាគ ប្រៀបធៀបបទប្បញ្ញត្តិពាក់ព័ន្ធនានា ដោយគូសបញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទនៃបញ្ហាប្រឈម យន្តការ និង/ឬវិធានការដែលចាំបាច់ដើម្បីដោះស្រាយ លប់បំបាត់ ឬបញ្ចៀសភាពស្រពិចស្រពិលផ្សេងៗ បញ្ហាបដិប្បញ្ញត្តិ បញ្ហាវិវាទយុត្តាធិការ បញ្ហាសង្កតភាពខាងគោលការណ៍ទូទៅ និង/ឬវិធានគតិយុត្តសម្រាប់ធានាប្រសិទ្ធភាពអនុវត្តជាដើម

ង. សិក្សា វិភាគ ប្រៀបធៀបនិងចង្អុលបង្ហាញច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដែលត្រូវធ្វើវិសោធនកម្ម ឬនិរាករណ៍ អនុលោមតាមការចាំបាច់

ច. រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួន ជូនក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ព្រមទាំងកំណត់បង្ហាញ និងសេចក្តីថ្លែងហេតុនានា។

ឆ. ចូលរួមប្រជុំ និងវេទិកាផ្សេងៗ តាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

ជ. បំពេញភារកិច្ចផ្សេងទៀត តាមការចាំបាច់ ឬតាមការចាត់តាំងរបស់ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន។

**ប្រការ ១៥.–**

ក្រុមការងារគ្រប់គ្រងការស្រាវជ្រាវនិងអាជីវកម្មរ៉ែ ជាសេនាធិការនៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោក | **ឡុង រិទ្ធីរក្សា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន | ប្រធាន |
| ២- លោក | **អ៊ុំ ឧត្តី** | អនុប្រធាននាយកដ្ឋានអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ | អនុប្រធាន |
| ៣- លោក | **ជា ឡេង** | ប្រធានការិយាល័យនៃនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | សមាជិក |
| ៤- តំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ | | | សមាជិកអញ្ជើញ |
| ៥- អ្នកជំនាញការជាតិ និង/ឬអន្តរជាតិ | | | សមាជិកអញ្ជើញ |

ប្រធានក្រុមការងារបច្ចេកទេស ឬ ក្រុមការងារគ្រប់គ្រងការស្រាវជ្រាវនិងអាជីវកម្មរ៉ែ អាចស្នើសុំបន្ថែមសមាជិករបស់ខ្លួន តាមការចាំបាច់។ ការតែងតាំងនេះត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ ១៦.–**

ក្រុមការងារគ្រប់គ្រងការស្រាវជ្រាវ រុករកនិងធ្វើអាជីវកម្មរ៉ែ មានតួនាទី និងភារកិច្ចជាសារវន្តដូចខាងក្រោម៖

ក.សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគប្រៀបធៀបច្បាប់ បទដ្ឋានគតិយុត្តជាធរមាន និងបទពិសោធន៍ល្អៗដែលមាន ដើម្បីស្នើចេញនូវខ្លឹមសារនៃសេចក្តីព្រាងបទប្បញ្ញត្តិនានាសម្រាប់ជំរុញនិងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រើប្រាស់ ការអាស្រ័យផលតាមគ្រប់រូបភាពលើធនធានរ៉ែគ្រប់ប្រភេទ សំដៅរួមចំណែកជានាឱ្យបាននូវការអភិវឌ្ឍន៍ជាតិមាតុភូមិ ប្រកបដោយចីរភាព និងសមធម៌ ស្របតាមគោលការណ៍នៃការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប (តាមរយៈការដាក់បញ្ចូលនូវការធ្វើសនិទានកម្មលើគ្រប់ទិដ្ឋភាព) ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីជាប្រយោជន៍ដល់ការកសាងបរិស្ថានរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតដ៏ស្រស់បំព្រង ពេញបរិបូណ៌ដោយសុវត្ថិភាព សម្រាប់មនុស្ស និងជីវៈចម្រុះនានារស់នៅ ប្រកបដោយផាសុកភាព និងភាពសុខដុមរម្យនាជានិរន្តន៍នឹងគ្នា

ខ.បង្កើតយន្តការនិងវិធានគតិយុត្តនានា ដែលចាំបាច់សម្រាប់លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបង្ការ ការកាត់បន្ថយ និង/ឬលុបបំបាត់ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន ចំពោះបរិស្ថាន សុខភាពមនុស្ស សត្វ រុក្ខជាតិនិងជីវៈចម្រុះនានាផ្សេងទៀត ជាអាទិ៍៖

- កំណត់ឋានានុក្រមបទដ្ឋានគតិយុត្ត លិខិតគតិយុត្ត សេចក្តីសម្រេច ឬលិខិតគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងអាងស្តុកទឹក ការប្រើប្រាស់ទឹក បុរាណដ្ឋាន មណ្ឌលវប្បធម៌ អារ្យធម៌ នគរូបនីយកម្ម និងការរៀបចំក្រុងដោយនិរន្តរភាព និងការធ្វើការសិក្សា ស្រាវជ្រាវ រុករក ព្រមទាំងការដំណើរការអាជីវកម្ម ក៏ដូចជាបញ្ហាពាក់ព័ន្ធផ្សេងទៀត
- ការដាក់បញ្ចូលយន្តការនៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ទៅក្នុងយន្តការគ្រប់គ្រងនិងបង្ការហានិភ័យដែលអាចកើតមានក្នុងវិស័យធនធានរ៉ែ
- បង្កើតបទប្បញ្ញត្តិពិសេសនានាដែលចាំបាច់ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងតាមប្រភេទរ៉ែនានាដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា (ជាអាទិ៍៖ រ៉ែប្រេងកាត និងឧស្ម័ន រ៉ែមាស រ៉ែដែក រ៉ែលោហៈផ្សេងៗទៀត ខ្សាច់ និងរ៉ែផ្សេងទៀត)
- បង្កើតនូវបទដ្ឋានគតិយុត្តនានាដែលចាំបាច់ ដើម្បីសម្រួលនិងលើកកម្ពស់ប្រសិទ្ធភាពនៃការទាញយកផលប្រយោជន៍ពីការអាស្រ័យផល តាមគ្រប់រូបភាពលើធនធានរ៉ែ តាមរយៈការពិចារណាជាអាទិ៍៖ ទៅលើលទ្ធភាពក្នុងការធ្វើទំនើបកម្មនយោបាយហិរញ្ញប្បទាន ការកែសម្រួលបែបបទ នីតិវិធី និងក្របខណ្ឌច្បាប់នានាឱ្យមានលក្ខណៈស៊ីសង្វាក់ជាមួយនឹងនិយាមអន្តរជាតិពាក់ព័ន្ធ ការធ្វើទំនើបកម្មប្រព័ន្ធធានារ៉ាប់រង ការធ្វើទំនើបកម្មវិធានការគ្រប់គ្រងហានិភ័យនិងសុវត្ថិភាព ការកែលម្អតួនាទីអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់អនុលោមតាមនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ។ល។

គ.សិក្សា វិភាគនិងស្នើវិធានការនានាដែលចាំបាច់សម្រាប់គាំពារនិងលើកទឹកចិត្តប្រជាជនឱ្យចូលរួមកែលម្អផ្នត់គំនិត និងរបៀបរស់នៅឱ្យបានសមស្របតាមគោលការណ៍ និងបទដ្ឋានគតិយុត្តថ្មី តាមរយៈការកំណត់សិទ្ធិ សេរីភាព កាតព្វកិច្ច និងករណីយកិច្ចជូនបុគ្គលដែលទទួលបានអាណត្តិពីរដ្ឋ ពីរាជរដ្ឋាភិបាល ឬពីរាស្ត្រ មន្ត្រីរាជការសាធារណៈ កងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ ប្រជាជនគ្រប់រូប និងបុគ្គលដទៃទៀតដែលបង្កើតដោយច្បាប់

ឃ.បង្កើតមូលដ្ឋានគ្រឹះនៃការកសាងនិងអភិវឌ្ឍយន្តការនានាដែលចាំបាច់សម្រាប់គាំពារដល់ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ដោយរួមបញ្ចូលទាំងការបង្កើតប្រព័ន្ធលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ការទូទាត់សេវាបរិស្ថាន ការបង្កើតនយោបាយពន្ធដារ ប្រព័ន្ធវិនិយោគ ការគ្រប់គ្រងនិងតម្រង់ទិសដំណើរវិវត្តន៍នៃចរន្តសេដ្ឋកិច្ចទីផ្សារ អនុលោមតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ

ង. បង្កើតវិធានគតិយុត្តនានាដែលចាំបាច់សម្រាប់បង្កើត លើកកម្ពស់ និងគាំពារដល់ការដាក់ឱ្យអនុវត្តយ៉ាងទូលំទូលាយលើផ្ទៃប្រទេស នូវការសិក្សា ស្រាវជ្រាវ និងចរាចរណ៍ផលិតផលបច្ចេកវិជ្ជា និងវិធីសាស្ត្រនានាដែលគាំពារដល់ចំណុចទាំងអស់ខាងលើ

ច. សិក្សា វិភាគ ប្រៀបធៀបនិងចង្អុលបង្ហាញច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលត្រូវធ្វើវិសោធនកម្ម ឬនិរាករណ៍ អនុលោមតាមការចាំបាច់

ធ. រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួន ជូនក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន ព្រមទាំង កំណត់បង្ហាញ និងសេចក្តីថ្លែងហេតុនានា

ជ. ចូលរួមប្រជុំ និងវេទិកាផ្សេងៗ តាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

ឈ.បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន។

**ប្រការ ១៧.-**

ក្រុមការងារអភិវឌ្ឍន៍កិច្ចការស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន ជាសេនាធិការនៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោក | **រាត់ សិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន | ប្រធាន |
| ២- លោក | **ឈុន ខណ្ណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន | អនុប្រធាន |
| ៣- លោក | **គុំ ខាសនា** | អនុប្រធាននាយកដ្ឋានព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន | សមាជិក |
| ៤- លោក | **គង់ សៀកលី** | អនុប្រធាននាយកដ្ឋានអប់រំបរិស្ថាន | សមាជិក |
| ៥- តំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ | | | សមាជិកអញ្ជើញ |
| ៦- អ្នកជំនាញការជាតិ និង/ឬអន្តរជាតិ | | | សមាជិកអញ្ជើញ |

ប្រធានក្រុមការងារបច្ចេកទេស ឬប្រធានក្រុមការងារអភិវឌ្ឍន៍កិច្ចការស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន អាចស្នើសុំបន្ថែមសមាជិករបស់ខ្លួន តាមការចាំបាច់។ ការតែងតាំងនេះត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ ១៨.-**

ក្រុមការងារអភិវឌ្ឍន៍កិច្ចការស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

ក.សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគប្រៀបធៀបច្បាប់ បទដ្ឋានគតិយុត្តជាធរមាន និងបទពិសោធន៍ល្អៗដែលពាក់ព័ន្ធនឹងកិច្ចការអប់រំសិស្ស និស្សិត វិនិយោគិនជាតិ អន្តរជាតិ និងប្រជាជនទូទៅ ដើម្បីស្នើចេញនូវខ្លឹមសារនៃសេចក្តីព្រាង បទប្បញ្ញត្តិពាក់ព័ន្ធនានា សំដៅជានាប្រសិទ្ធភាពនៃការកែលម្អផ្នត់គំនិត របៀបរបបរស់នៅ និងប្រកបអាជីវកម្មរបស់ប្រជាជន វិនិយោគិនជាតិ អន្តរជាតិ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ឱ្យស្របតាមស្មារតីនៃសេចក្តីព្រាងក្រមបរិស្ថាន

ខ.បង្កើតយន្តការនិងវិធានគតិយុត្តនានា ដែលចាំបាច់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមរយៈការបង្កើតយន្តការលើកទឹកចិត្ត (នយោបាយពន្ធដារ ការផ្តល់រង្វាន់ ការប្រឡងប្រណាំង ការបន្ធូរបន្ថយទោស ឬការទទួលខុសត្រូវ...) ត្រួតពិនិត្យ តាមដាន ឃ្លាំមើល ស៊ើបអង្កេត និងយន្តការដាក់ទណ្ឌកម្មនានា (ការព្យួរ ឬបិទសង្វាក់ផលិតកម្ម ការពិន័យ ការដកហូតអាជ្ញាប័ណ្ណ ការបណ្តេញចេញពីវិជ្ជាជីវៈ ការដាក់ពន្ធនាគារ។ល។)

គ.បង្កើតមូលដ្ឋានគ្រឹះនៃការកសាងនិងអភិវឌ្ឍយន្តការនានាដែលចាំបាច់ សម្រាប់ជួយបំលែងការសិក្សាស្រាវជ្រាវ រុករក និង/ឬផ្សព្វផ្សាយឱ្យក្លាយជាកម្លាំងចលករសម្រាប់ឈានទៅដល់ការបង្កើតថ្មី (នវានុវត្តន៍) ក៏ដូចជាការបង្កើតឱកាសធុរកិច្ចដ៏មានសក្តានុពលដោយផ្សារភ្ជាប់របកគំហើញខាងបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រ ជាមួយនឹងកិច្ចការអភិវឌ្ឍសិប្បកម្ម និង/ឬឧស្សាហកម្មជាដើម

ឃ.បង្កើតបទដ្ឋានគតិយុត្តនិងយន្តការគាំពារនានាដើម្បីលើកទឹកចិត្តឱ្យគ្រប់ស្ថាប័នរដ្ឋ (រួមមានថ្នាក់ដឹកនាំស្ថាប័ន កម្លាំងប្រដាប់អាវុធ មន្ត្រីរាជការទូទៅ មន្ត្រីអនុវត្តច្បាប់ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់) ចាប់យកគោលការណ៍និងបទប្បញ្ញត្តិក្នុងសេចក្តីព្រាងក្រមបរិស្ថានធ្វើជាមាគ៌ាសម្រាប់គូសវាស រៀបចំការិយាល័យ បរិយាកាសការងារ និងឥរិយាបទប្រចាំថ្ងៃរបស់ខ្លួន ដូចជា៖ នយោបាយឧបត្ថម្ភធន ការដាក់ឱ្យរួចពន្ធ ឬជាប់ពន្ធតាមរបបបន្ធូរបន្ថយ ចំពោះករណីកិច្ចការលទ្ធកម្មបច្ចេកវិជ្ជា ឬវិទ្យាសាស្ត្របែបមេត្រីបរិស្ថានដែលធ្វើដោយស្ថាប័នរដ្ឋជាដើម ការប្រើប្រាស់ថាមពលអគ្គិសនី -ទឹក ការរៀបចំសួនលម្អ និងអនាម័យបរិស្ថាន ការសាងសង់សំណង់មេត្រីបរិស្ថាន ការរៀបចំក្រុង ការចូលរួមថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ព្រៃឈើ និងជីវៈចម្រុះនានា។ល។

ង. សិក្សា វិភាគ ប្រៀបធៀប និងចង្អុលបង្ហាញអំពីច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលត្រូវធ្វើវិសោធនកម្ម ឬនិរាករណ៍ អនុលោមតាមការចាំបាច់

ច. ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួនជូនក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន។

ឆ. ចូលរួមប្រជុំ និងវេទិកាផ្សេងៗ តាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

ជ. បំពេញភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន។

**ប្រការ ១៩.-**

ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាននេះ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងបរិស្ថាន ទទួលជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងអាចប្រើប្រាស់ថវិកាក្រសួងបរិស្ថានក្នុងករណីចាំបាច់។

**ប្រការ ២០.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធនធានធម្មជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដាឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ